# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានរៀបចំ “**សិក្ខាសាលាពិគ្រោះយោបល់លើការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០១៥**” ក្រោមអធិបតីភាពឯកឧត្តម **រស់ សីលវ៉ា** អគ្គលេខាធិការ នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយមានការចូលរួមពីតំណាងគ្រប់ក្រសួងស្ថាប័ន ព្រមទាំងតំណាងដៃគូអភិវឌ្ឍន៍។

សិក្ខាសាលាពិគ្រោះយោបល់នាថ្ងៃនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយទូលំទូលាយនូវសេចក្តីព្រាងរបាយការណ៍លទ្ធផលនៃការវាយតម្លៃលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០១៥ និងដើម្បីទទួលបាននូវធាតុចូលបន្ថែមពីអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន សំដៅកែលម្អរបាយការណ៍វាយតម្លៃលើប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ឱ្យកាន់តែមានសុក្រឹតភាព និងភាពគ្រប់ជ្រុងជ្រោយ ដើម្បីជាមូលដ្ឋានសម្រាប់រៀបចំផែនការសម្មភាពរួមដំណាក់កាលទី៣ (Consolidated Action Plan Stage 3, CAP3) ជាពិសេស ដំណាក់កាលទី៣ គឺការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ឬ ការអនុវត្តថវិកាកម្មវិធី។

យើងបានប្រើប្រាស់នូវយន្តការវាយតម្លៃ “**ចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ**” ដែលហៅកាត់ថាPEFA ដើម្បីវាយតម្លៃលើស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងមូល របស់រាជរដ្ឋាភិបាលកម្ពុជា ធៀបជាមួយឧត្តមានុវត្តន៍និងស្តង់ដារអន្តរជាតិ ដែលមាន **៣១** សូចនាករសមិទ្ធកម្ម ដែលក្នុងនោះ ២៨សូចនាកសមិទ្ធកម្ម ផ្តោតលើសមត្ថកិច្ចរបស់រដ្ឋាភិបាល និង **០៣** សូចនាករសមិទ្ធកម្មពាក់ព័ន្ធនឹងប្រទេសម្ចាស់ជំនួយ។ បើធៀបនឹងលទ្ធផលនៃការវាយតម្លៃលើកទី១ នៅឆ្នាំ២០១០ លទ្ធផលបឋមនៃការវាយតម្លៃលើកទី២ ឆ្នាំ២០១៥ នេះ បាននិងកំពុងស្ថិតនៅលើវិថីវឌ្ឍនាការរីកចម្រើនដ៏គួរជាទីសង្ឃឹមក្នុងការប្តូរផ្តាច់មោះមុតខិតខំអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងរយៈពេល ១០ ឆ្នាំ កន្លងមកនេះ។

វឌ្ឍនភាពដ៏គួរជាទីលើកទឹកចិត្តនេះ គឺជាសមិទ្ធផលដែលកើតចេញពីឆន្ទៈនយោបាយដ៏មុតស្រួចនិងឥតរាថយ និងការកំណត់ទិសដៅនិងយុទ្ធសាស្ត្រដ៏ត្រឹមត្រូវនិងប្រាកដនិយម របស់រាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹងការចង្អុលណែនាំផ្ទាល់ជាប្រចាំរបស់ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គួបផ្សំនឹងការខិតខំប្រឹងប្រែងអនុវត្តរបស់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួង ស្ថាប័នទាំងអស់ នៃព្រះរាជាណាចក្រកម្ពុជា

យោងតាមរបាយការណ៍បូកសរុបរបស់ឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន** អគ្គលេខាធិការរង នៃអគ្គ-លេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សិក្ខាសាលាបានដំណើរការ ដោយរលូន មានការជជែកវែកញែកពិភាក្សាយ៉ាងសកម្ម រស់រវើក ផុលផុស និងបង្កើតបានជាធាតុចូលយ៉ាងច្រើនជាពិសេស តាមរយៈសំនួរ-ចម្លើយលើបទបង្ហាញ និងលទ្ធផលដែលទទួលបានមកពីក្រុមពិភាក្សានីមួយៗ នឹងធ្វើជាមូលដ្ឋានក្នុងការដោះស្រាយនូវបញ្ហាប្រឈមនិងសម្រាប់កែលម្អរបាយការណ៍ PEFA ប្រកបដោយសុក្រឹត្យភាព និងគ្រប់ជ្រុងជ្រោយ ។